# សម្ភាសន៍ជាមួយឈ្មោះ ទី មឿន ភេទប្រុស អាយុ៦៣ឆ្នាំ
## មុខងារសម័យខ្មែរក្រហមៈ នៅក្នុងកងចល័ត
## ស្រុកកំណើតនៅភូមិដាក់សរសរ ឃុំឱម៉ាល់ ស្រុកបាត់ដំបង ខេត្តបាត់ដំបង
## សព្វថ្ងៃរស់នៅភូមិយាងវៀន ឃុំផ្គាំ ស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ
## ថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០១០
## សម្ភាសន៍ដោយៈ ឡុង ដានី
## ២០ទំព័រ

ដានីៈ អញ្ជឹងជំរាបសួរ ខ្ញុំសុំស្គាល់ឈ្មោះពូ តើពូឈ្មោះអី?

មឿនៈ ខ្ញុំឈ្មោះ ទី មឿន ។

ដានីៈ អាយុប៉ុន្មានហើយ?

មឿនៈ មិនដឹងអាយុប៉ុន្មានទេសព្វថ្ងៃ ដឹងតែឆ្នាំម្សាញ់ប្រហែលជា៦០ហើយ ។

ដានីៈ ពូកើតឆ្នាំ១៩០០ប៉ុន្មាន?

មឿនៈ មិនដឹងជាឆ្នាំ១៩៤៧ឬក៏១៩៥៧ទេ ។

ដានីៈ អញ្ជឹងឥលូវ៦០ប៉ុន្មានហើយ?

មឿនៈ ៦៣ហើយ ។

ដានីៈ ពូមានស្រុកកំណើតនៅណាដែរ?

មឿនៈ ខ្ញុំមានស្រុកកំណើតនៅភូមិដាក់សរសរ ឃុំឱម៉ាល់ ។

ដានីៈ ស្រុកអីគេ?

មឿនៈ ស្រុកបាត់ដំបង ខេត្តបាត់ដំបង ។

ដានីៈ ចុះសព្វថ្ងៃរស់នៅភូមិអីដែរ?

មឿនៈ ភូមិនេះភូមិយាងវៀន ឃុំផ្គាំ ស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ ។

ដានីៈ គ្រួសារមីងឈ្មោះអីដែរ?

មឿនៈ ឈ្មោះវ៉ន វឿត ។

ដានីៈ សព្វថ្ងៃមីងអាយុប៉ុន្មានហើយ?

មឿនៈ អាយុ៤៨ឆ្នាំ ។

ដានីៈ អាយុ៤៨?

មឿនៈ បាទ!

ដានីៈ ពូមានកូនចៅប៉ុន្មាននាក់ហើយ?

មឿនៈ កូនចៅមាន៤នាក់។

ដានីៈ ស្រីប៉ុន្មានប្រុសប៉ុន្មាន?

មឿនៈ ស្រី២នាក់ ប្រុស២នាក់។

ដានីៈ ពូប្រកបមុខរបរធ្វើអីដែរ?

មឿនៈ សព្វថ្ងៃធ្វើស្រែ តែមិនមានច្រើនប៉ុន្មានទេអូនអើយ មានតែបន្តិចបន្តួចសម្រាប់មួយហូបហ្នឹង។

ដានីៈ ធ្វើតែស្រែអត់មានធ្វើអីទៀតទេ?

មឿនៈ បាទ!

ដានីៈ ចុះឪពុកម្តាយពូឈ្មោះអី?

មឿនៈ ឪពុកខ្ញុំឈ្មោះអីទេ កាលហ្នឹងគាត់ធ្វើមេខ្មែរក្រហមកាលសម័យពីដើម គាត់មេខ្មែរក្រហមសុទ្ធសាទហ្នង។

ដានីៈ គាត់ឈ្មោះអីដែរ?

មឿនៈ ឈ្មោះសួន ញៀត។

ដានីៈ សព្វថ្ងៃគាត់ស្លាប់ហើយ?

មឿនៈ បាទ!គាត់ស្លាប់ហើយ។

ដានីៈ គាត់ស្លាប់តាំងពីអង្កាល់?

មឿនៈ គាត់ស្លាប់កាលនេះចូលមកហ្នឹង។

ដានីៈ ឆ្នាំ៧៩?

មឿនៈ នៅក្នុងចំណោមនោះឯង ពួកខ្មែរក្រហមមកហើយវាចាប់យើងសម្លាប់ណា។

ដានីៈ ពួននារតីចាប់ហ្នឹងមែន?

មឿនៈ បាទ! ខ្ញុំវាចាំមិនបានណាកាលសម័យនោះ គាត់ជាមេខ្មែរក្រហមដល់ពេលគេចូលមកគេសម្លាប់គាត់។

ដានីៈ ចុះម្តាយលោកពូ?

មឿនៈ ម្តាយឈ្មោះទី ហាច។

ដានីៈ សព្វថ្ងៃគាត់នៅរស់ឬស្លាប់បាត់ហើយ?

មឿនៈ គាត់ស្លាប់ហើយ។

ដានី៖ គាត់ស្លាប់តាំងពីពេលណា?

មឿន៖ ស្លាប់នៅក្នុងឆ្នាំ៧៩ ។

ដានី៖ ចុះពូមានបងប្អូនបង្កើតប៉ុន្មាននាក់?

មឿន៖ មានបងប្អូនបង្កើត៣នាក់ ។

ដានី៖ ស្រីប៉ុន្មាន ប្រុសប៉ុន្មាន?

មឿន៖ ប្រុស១ ស្រី២នាក់ ។

ដានី៖ ប្រុសតែពូមួយអញ្ចឹង?

មឿន៖ បាទ! ប្រុសតែខ្ញុំមួយ ។

ដានី៖ ពូកូនទីប៉ុន្មាន?

មឿន៖ ខ្ញុំកូនទី២ ។

ដានី៖ កាលពីក្មេងៗមានបានរៀនសូត្រដែរអត់?

មឿន៖ ខ្ញុំរៀនបានត្រឹមថ្នាក់ទី៦ ។

ដានី៖ រៀនដល់ថ្នាក់ទី៦?

មឿន៖ បាទ!

ដានី៖ ពូរៀននៅសាលាណា?

មឿន៖ រៀននៅសាលាបឋមសិក្សាអណ្តូងព្រីង បន្ទាប់មកចូលរៀននៅសាលាអៀបឃុត អៀបឃុតយើងនៅអូរបែកចាននៅបាត់ដំបង ។

ដានី៖ ពូឈប់រៀននៅឆ្នាំណា?

មឿន៖ កាលឈប់រៀនហ្នឹងមិនដឹងឆ្នាំណាទេអូនអើយ ។

ដានី៖ ឈប់រៀនមុនរដ្ឋប្រហារឆ្នាំ៧០ឬក៏ក្រោយឆ្នាំ៧០?

មឿន៖ មុនឆ្នាំ៧០ ។

ដានី៖ ឈប់តាំងពីមុនឆ្នាំប្រហារទម្លាក់សម្តេចទៀត?

មឿន៖ ខ្ញុំមានអតីតឈប់រៀនហើយបួសតែម្តង ។

ដានី៖ ឈប់រៀនហើយបួស?

មឿន៖ បាទ! បួសបានប៉ុន្មានវស្សាដែរ?

ដានី៖ បួសបានប៉ុន្មានវស្សា?

មឿនៈ បួសបានប្រហែលជា៣វស្សា  កាលនោះមានអាសន្នហើយឈប់រៀន  ដល់ពេលឈប់រៀនទៅបួសដល់ពេលបួសរួច  សឹកពីបួសគេចូលដល់តែម្តងតែគេមិនបានសឹកទេណា៎ យើងសឹកបានមុន ។

ដានីៈ  អញ្ចឹងដល់ពេលឆ្នាំ៧៥ហ្នឹងសឹកហ្មង?

មឿនៈ បាទ!

ដានីៈ  បួសនៅវត្តណា?

មឿនៈ បួសនៅវត្តបឹងរាំង ។

ដានីៈ  ដល់ពេលសឹកហើយធ្វើអីទៅ?

មឿនៈ ដល់ពេលសឹកហើយខ្មែរក្រហមគេឲ្យទៅនៅចល័ត  កាលឆ្នាំ៧៥ហ្នឹងគេចូលមកដល់តែម្តង  កាលឆ្នាំ៧៥អត់មានមុខរបរអីទេអូន  កាលហ្នឹងសឹកហើយគេចូលមកដល់ចល័តនឹងគេទៅ  បែកចែកចេញពីស្រុកពីស្រែទៅកើតចល័តហ្នឹងហ្មង ។

ដានីៈ  គេបញ្ចូលក្នុងកងចល័តហ្មង?

មឿនៈ បាទ!  គេបញ្ចូលក្នុងកងចល័ត ។

ដានីៈ  កងចល័តឲ្យទៅនៅណាទៅ?

មឿនៈ ឲ្យមកនៅអូរតាគី ។

ដានីៈ  ឲ្យមកនៅអូរតាគី  ធ្វើអីទៅនៅកងចល័តហ្នឹង?

មឿនៈ គេឲ្យដកស្ទូង  រាស់ហើយនឹងកាន់គោកាន់ក្របីហ្នឹងឯង  លើកទំនប់លើកអីហ្នឹង ។

ដានីៈ  គ្នាច្រើនទេកងចល័ត?

មឿនៈ កងចល័តដែលខ្ញុំនៅហ្នឹងមានគ្នា១០០០នាក់អាហ្នឹងផ្នែកខាងប្រុស  ហើយផ្នែកខាងស្រីក៏១០០០នាក់ដែរ  គេឲ្យនៅផ្សេងគ្នាកន្លែងគេធ្វើ ។

ដានីៈ  អ្នកកងចល័តហ្នឹងសុទ្ធតែជាអ្នកយ៉ាងម៉េច?

មឿនៈ បើនិយាយទៅកងចល័តហ្នឹងគេដាក់អញ្ចេះណាអូន  គេហៅថាប៉ែកខាងកូននាយទុននោះផ្សេង  ហើយអ្នកក្រីក្រនោះផ្សេង  ហើយកូនកសិករនោះគេដាក់ដោយឡែក  ហើយគេយកទៅរៀនសូត្រមួយយប់១០នាក់  ដូនកាលមួយយប់២០នាក់ក៏មានកាលសម័យនោះ ។

ដានីៈ  អ៎ឲ្យតែកូននាយទុនអីហ្នឹងគេយកទៅរៀនសូត្រ?

មឿនៈ បាទ!  នៅមិនបានយូប៉ុន្មានទេគេយកទៅរៀនសូត្រ  កាលនៅនោះយ៉ាប់ណាស់  ចល័តហើយខ្ញុំគ្មានពេលបានបាយហូបទេ  តែបបរវាល់វែកហ្នឹង  វាល់វែកមួយវែកកំពង់  ដល់ពេលរដូវប្រាំងគេឲ្យទៅលើកទំនប់នៅកំពីងពួយ  ដល់ពេលដល់រដូវវស្សាគេឲ្យទៅធ្វើស្រែ ។

ដានី៖ លើកទំនប់ធ្វើអី?

មឿន៖ ទំនប់កំពីងពួយអាងកំពីងពួយ ។

ដានី៖ ខែវស្សាធ្វើស្រែ?

មឿន៖ បាទខែវស្សាធ្វើស្រែ ។

ដានី៖ ធ្វើស្រែនៅណា?

មឿន៖ ធ្វើនៅម្តុំអូរតាគី វាលទ្រា ខ្សែលួស ។

ដានី៖ អញ្ចឹងកាលនៅកងចល័តហ្នឹងគេយកទៅសម្លាប់តែពួកកូននាយទុនទេ?

មឿន៖ គេសម្លាប់ពូជនាយទុន ហើយសម្លាប់ពូជខុសសិលធម៌ ហើយពួកដូចថាចល័តគ្នាឃ្លានខ្លាំងគ្នាលួចទឹកដោះ លួចដំឡូង លួចស្អីអញ្ចឹងទៅឲ្យតែគេឃើញសម័យនោះគេសម្លាប់ចោលហើយ ហើយដូចខ្ញុំផ្ទាល់អញ្ចឹងអ្នកកាន់គោកាន់ក្របីគេចងមួយយប់មួយថ្ងៃនៅដើមស្វាយ គេថាខ្ញុំក្បត់អង្គការត្រង់ថាគោក្របីដាច់ស៊ីស្រូវគេពេលយប់ បានឈ្មោះតាឆាំៗយើងគណៈស្រុកនៅភ្នំសំពៅនោះគាត់មកជួយកុំអីលាចាកលោកបាត់ហើយ ។

ដានី៖ គោហ្នឹងស៊ីអីបានគេចង?

មឿន៖ ស៊ីស្រូវ ព្រោះអីវាដាច់យប់ណាំ វាស៊ីមិនឆ្អែតហ្នឹងបានវាដាច់យប់ ដល់ពេលដាច់យប់គេថាខ្ញុំហ្នឹងខ្លាំងស៊ីរូងផ្ទៃក្នុងណាគេទេ ដល់ហើយគេចាប់យកទៅចងនៅដើមស្វាយ ។

ដានី៖ ចងនៅដើមស្វាយយូទេ?

មឿន៖ ចងមួយយប់ដល់ពេលព្រឹកឡើងគេប្រុងយកចេញហើយហ្នឹងបានតាឆាំគណៈស្រុកនៅភ្នំសំពៅគាត់ឲ្យលែង ។

ដានី៖ ម៉េចបានគាត់លែង?

មឿន៖ មិនដឹងម៉េចដែរព្រោះគាត់ទើបតែមកដល់បែបគាត់មានចិត្តអាណិតស្រណោះអី ពេលគាត់មកដល់ក្លាមគាត់ឲ្យលែង ។

ដានី៖ គាត់ឲ្យលែងយ៉ាងម៉េច?

មឿន៖ គាត់ប្រាប់អាមួយឈ្លបឲ្យដោះលែងទៅ ដួលឲ្យធ្វើការតទៅទៀត ខ្ញុំថាខ្ញុំស្លាប់ពេលនោះហើយតែវាគុណបុណ្យលោកជួយ សម័យនោះសម័យតាឆាំគាត់ធ្វើគណៈស្រុក ហើយប្រធានឃុំដែលខ្ញុំនៅអូរតាគីហ្នឹងឈ្មោះតាហៀក ។

ដានី៖ តាហៀកហ្នឹងមកពីណាមក?

មឿនៈ គាហៀកហ្នឹងមិនដឹងជាគាត់នៅភូមិណាទេ ហើយគាហៀកហ្នឹងគាត់ស្លាប់ដូចឪពុកខ្ញុំដែរ កាលដែលគេចូលមកហ្នឹងក៏គេសម្លាប់ទៅ ។

ដានីៈ ឪពុកពូគាត់ធ្វើអី?

មឿនៈ ឪពុកខ្ញុំកាលពីដើមគាត់កាន់បើតាមនិយាយសព្វថ្ងៃគេហៅវរៈសេនាតូចអញ្ចឹងណា តែនៅដោយឡែក ពួកខ្ញុំនេះនៅក្នុងស្រុកហើយគាត់ទៅនៅខាងខ្មែរក្រហម ម្លោះហើយគាត់គ្នាដោយឡែក ឪពុកនៅខាងនោះទៅ ហើយកូននេះនៅខាងក្នុងនេះ ហើយចូលមកដល់ខ្មែរក្រហមនេះគាត់អ្នកធំ យើងទៅលេងមួយភ្លែតៗតែសម័យនោះគេមិនឲ្យចេញចូលទេ ចំណែកម្តាយខ្ញុំនៅខាងក្នុងនេះមានតែគាត់ទេដែលរត់ទៅខាងក្រៅ គាត់មានមូលហេតុគាត់អីផ្សេងទៅណា ។

ដានីៈ ចុះពូស្គាល់តាឆាំច្បាស់ទេ?

មឿនៈ ច្បាស់ តាឆាំមានមាឌល្អិត ។

ដានីៈ ចុះមានស្គាល់អឿនទេ?

មឿនៈ ស្គាល់ ។

ដានីៈ អឿនហ្នឹងគាត់គណៈស្រុកដែរ?

មឿនៈ បាទ!

ដានីៈ ចុះគណៈតំបន់?

មឿនៈ គណៈតំបន់ខ្ញុំចាំមិនបានទេ ។

ដានីៈ ចាំអត់បានទេ?

មឿនៈ បាទ!

ដានីៈ ពូនៅតំបន់ប៉ុន្មាន?

មឿនៈ ខ្ញុំនៅតំបន់៣ ។

ដានីៈ មានដែលស្គាល់ឈ្មោះតាគុំទេ?

មឿនៈ តាគុំគ្រាន់តែម៉ាព្ទឈ្មោះ ។

ដានីៈ ចុះគណៈភូមិភាគ?

មឿនៈ គណៈភូមិភាគចាំឈ្មោះគាត់មិនបាន ដូចថាយើងជាចល័តសាម័ញ្ញ ។

ដានីៈ ចុះតាញឹម?

មឿនៈ តាញឹមស្គាល់ ។

ដានីៈ ស្គាល់?

មឿនៈ បាទ!

ដានីៈ គាត់ធ្វើអី? .

មឿនៈ មិនដឹងជាគណៈស្រុកឬគណៈភូមិភាគនោះទេ ព្រោះខ្ញុំធ្លាប់ឃើញមុខគាត់ កាលសម័យនោះគេហៅអង្គទិញណាអូន ហើយគាត់អង្គទិញទៅក្នុងកងចល័តទាំងអស់ ហើយក៏បានឃើញគាត់អញ្ចឹងបានខ្ញុំថាស្គាល់មុខគាត់ច្បាស់ ដូចថាស្គាល់ច្បាស់ ស្គាល់គ្នារាប់អានគ្នាដូចជាបងប្អូនអីមិនមែនទេ គ្រាន់ថាបានឃើញមុខគាត់ច្បាស់ ។

ដានីៈ កាលហ្នឹងមានតាញឹម តាគី តាអេង ទាវអី?

មឿនៈ ទេមិនដែលបានឃើញទេ គ្រាន់តែបានឮឈ្មោះ ។

ដានីៈ ចុះពូនៅកងចល័តរហូតឬក៏មានផ្លាស់ប្តូរអីដែរ?

មឿនៈ នៅកងចល័តរហូតដល់វៀតណាមចូលស្រុក ដល់ពេលមកដល់បាត់ដំបងគេកៀរទៅលិច ។

ដានីៈ ចុះពូដែលថាគេចាប់ចងពូមួយយប់ព្រោះធ្វើឲ្យគោជាច់មួយយប់ស៊ីស្រូវហ្នឹងឆ្នាំណា?

មឿនៈ ប្រហែលជាឆ្នាំ៧៦ ។

ដានីៈ ហ្នឹងពីណាគេជាអ្នកចាប់ចង?

មឿនៈ ឈ្លបនៅក្នុងភូមិហ្នឹង ។

ដានីៈ ហើយមានវ៉ៃពូទេ?

មឿនៈ វ៉ៃតើ ។

ដានីៈ ពេលវ៉ៃហ្នឹងគេថាយ៉ាងម៉េច?

មឿនៈ គេថាខ្ញុំហ្នឹងខ្មាំងស៊ីរូងផ្ទៃក្នុងបំផ្លាញទ្រព្យរបស់អង្គការ ។

ដានីៈ ហើយពូប្រាប់គេថាយ៉ាងម៉េច?

មឿនៈ ខ្ញុំថាខ្ញុំមិនមែនខ្មាំងទេ ខ្ញុំបានចងវាជាប់ដែរតែបែជន្យមិនដឹងយ៉ាងម៉េចបានវាដាច់ គេថាខ្ញុំហ្នឹងប្រកែកតវ៉ា គេថាអាមិត្តឯងតវ៉ាអញ្ចឹងបានគេវ៉ៃ វ៉ៃរួចហើយគេចងទុកចោលនៅហ្នឹងអន្រ្ទងខាំចង់ងាប់ ។

ដានីៈ អន្រ្ទងខាំទៀត?

មឿនៈ បាទ!

ដានីៈ ពូមានស្រែកឲ្យគេជួយទេ?

មឿនៈ មិនដឹងជាស្រែកឲ្យអ្នកណាជួយទេ ក្នុងមួយចំណោមនោះស្ងាត់ជ្រាបទាំងអស់ ដូចថាអ្នកកាន់គោ មាន១៣នាក់ភ្ជួររាស់ ស្ទូងឲ្យចល័តគេ ១៣នាក់នៅក្នុងនោះសុទ្ធតែគេចាប់ចង ហើយគ្នាសុទ្ធ តែស្ងាត់ជ្រាបទាំងអស់អត់មានអ្នកណាហ៊ាន ។

ដានីៈ អញ្ចឹងគណៈហ្នឹងតាហៀក?

មឿនៈ បាទ! តាហៀកហ្នឹងគាត់ប្រធាន គាត់ដូចថាប្រធានឃុំពីដើម ។

ដានីៈ ឈ្លបអ្នកចាប់ពូហ្នឹងពូស្គាល់គាត់ដែរ?

មឿនៈ ឈ្មោះមុំ ។

ដានីៈ អ្នកនៅស្រុកណា?

មឿនៈ ដូចជាគេហៅអ្នកស្រុករន្ធខាងលិចនេះ គេហៅភូមិរន្ធៗអាហ្នឹងស្រុកកំណើតគេ ។

ដានីៈ កាច?

មឿនៈ កាចណាស់អូនអើយ ។

ដានីៈ វ៉ៃពូ?

មឿនៈ បាទ! វ៉ៃខ្ញុំ ។

ដានីៈ ពូអត់ហ៊ានអង្វរគេទេ?

មឿនៈ មិនដឹងជាអង្វរយ៉ាងម៉េច សូម្បីតែមើលមុខគេក៏មិនហានមើល កាលសម័យនោះដូចជាមិនហ៊ាន គ្រាន់តែហ៊ានលើកដៃសំពះតែមាត់មិនហ៊ានមាត់ ។

ដានីៈ ឈ្លបមាន២នាក់?

មឿនៈ ឈ្លបទាំងអស់មាន៩នាក់ណា៎ តែគេអ្នកចាប់នោះមាន២នាក់ ហើយឈ្លបនៅកន្លែងនោះមាន៩ នាក់ ។

ដានីៈ ពូដែលឃើញគេយកមនុស្សទៅសម្លាប់ដែរទេ?

មឿនៈ ឃើញ ។

ដានីៈ ឃើញគេសម្លាប់ម៉េចទៅ?

មឿនៈ គេវ៉ៃនឹងត្បូងចបយើងនោះ បើកន្លែងនោះវ៉ៃហ្នឹងចបកាប់ឃើញសឹងរាល់ថ្ងៃ ។

ដានីៈ ឃើញផ្ទាល់ភ្នែកហ្នង?

មឿនៈ បាទ! ឃើញរាល់ថ្ងៃ ។

ដានីៈ របៀបគេវ៉ៃយ៉ាងម៉េច?

មឿនៈ គេដឹកអន្ទុងរួចគេឲ្យអង្គុយ ហើយគេចងដៃអញ្ចឹងដល់យើងអង្គុយគេវ៉ៃចោលតែម្តងទៅ ។

ដានី៖ គេវ៉ៃចំណា?

មឿន៖ គេវ៉ៃចំកន្លែងកញ្ជឹងកនេះហើយគេទម្លាក់ទៅក្នុងរណ្តៅ ។

ដានី៖ ចបកាប់យ៉ាងម៉េច?

មឿន៖ អាចបកាប់ អាប៉ូយចប អាខាងខ្នងចបហ្នឹង ។

ដានី៖ ខ្នងចបហ្នឹង?

មឿន៖ បាទ! វ៉ៃហ្នឹងខ្ញុំឃើញសឹងរាល់ថ្ងៃ ។

ដានី៖ ស្រែកទេអ្នកដែលត្រូវគេវ៉ៃ?

មឿន៖ ស្រែកតើ ។

ដានី៖ ស្រែកម៉េច?

មឿន៖ អាខ្លះស្រែកផ្តាំកូនផ្តាំចៅ ហើយមានអ្នកខ្លះស្រែកថាលាហើយពិភពលោក មានម្នាក់នោះមានចិត្តក្លាហាន គាត់ថាចិត្តខ្មៅក្តីហើយមានសិលធម៌នេះហើយ ពួកអ្នកចិត្តខ្មៅនៅក្រោយកុំយកហើយកុំទុកចិត្ត អាហ្នឹងគាត់និយាយអញ្ចឹងណា ។

ដានី៖ ហើយពូអត់ខ្លាចទេពេលដែលពូឃើញគាត់?

មឿន៖ ខ្លាចតើ តែមិនដឹងទៅណាព្រោះកន្លែងនោះវានៅជិតដែរ ខុទាររហាណ៍ថាកន្លែងគេនៅទីនេះហើយកន្លែងគេវ៉ៃដូចថាមានគុកខ្មោច កន្លែងគុកខ្មោចគេវ៉ៃនៅខាងក្រោយ ហើយកន្លែងបរិវេននោះខ្ញុំទៅមើលគោមើលក្របីនៅមុំហ្នឹងណា៎ ហើយកន្លែងជាកន្លែងស្រែកន្លែងភ្លឺអីទៅ កន្លែងហ្នឹងកន្លែងគោកន្លែងក្របី ខ្ញុំបានឃើញរាល់ថ្ងៃទាំងថ្ងៃទាំងយប់ ។

ដានី៖ ចុះខ្មែរក្រហមគេឲ្យយើងមើលដែរ?

មឿន៖ គេមិនឲ្យយើងនេះទេ គេគ្រាន់ដូចថាជាកន្លែងមើលគោមើលក្របី ញុំដល់ហើយនឹងមើលឃើញគេមិនឲ្យយើងមើលទេ ហើយយើងនៅកន្លែងនោះមើលទៅឃើញ មើលទៅច្បាស់ កន្លែងមើលគោមើលក្របីម្ខាងអូរនេះ ពេលគេចាប់ពីណាពីណីទៅគេយកទៅវ៉ៃតែកន្លែងហ្នឹង ។

ដានី៖ កន្លែងវ៉ៃហ្នឹងគេហៅកន្លែងអីគេ?

មឿន៖ គេហៅកន្លែងក្បាលស្ពានអូរតាគីហ្នឹង កើតត្បូងអូរខាងកើតស្ពាន ។

ដានី៖ ខាងកើតស្ពាន?

មឿន៖ បាទ!

ដានី៖ គេវ៉ៃច្រើនមែន?

មឿន៖ គេវ៉ៃច្រើនណាស់ វ៉ៃស្ទើររាល់ថ្ងៃ ។

ដានីៈ ពួកឈ្លបណាវៃ ឈ្មោះមុំអីហ្នឹង?

មឿនៈ បាទ!

ដានីៈ គេវៃគេអត់មានយកអីទេ?

មឿនៈ ឃើញមានជីនីស ។

ដានីៈ ជីនីសម៉េច?

មឿនៈ អាចបកាប់យើងហ្នឹង ។

ដានីៈ ហើយពេលគេវៃខោអាវគេមានដោះយកដែរ?

មឿនៈ ខោអាវអត់មានដោះយកទេ ទៅតែទាំងអស់ គេចងហើយឲ្យអង្គុយមាត់អន្ទុង ។

ដានីៈ អង្គុយមាត់អន្ទុង?

មឿនៈ បាទ! ហើយអាខ្លះវាខ្ជិលវាឲ្យជីកខ្លួនវា ។

ដានីៈ វៃស្មានម៉ាន?

មឿនៈ វៃច្រើនពេលល្ងាច បើវាត្រូវវៃថ្ងៃក៏មាន ព្រឹកក៏មាន អាខ្លះខុសសិលធម៌ អាខ្លះខ្ទាំងស៊ីរូងផ្ទៃក្នុងអាហ្នឹងតាមតែគេនិយាយដែរទេ ។

ដានីៈ ហើយចុះអ្នកទោសស្រីៗដែលគេត្រូវសម្លាប់ហ្នឹងគេមានរំលោភទេ?

មឿនៈ ទេមិនដែលបានឃើញទេអូនអើយ ។

ដានីៈ ហើយអ្នកសម្លាប់ហ្នឹងយ៉ាងម៉េចច្រើនតែប្រជាជនដែលនៅមូលដ្ឋានហ្នឹង ឬក៏ប្រជាជនថ្មី?

មឿនៈ ប្រជាជនថ្មី ដូចជាខ្ញុំបាទនៅគេឲ្យចល័តទៅនៅអញ្ចឹងណា៎ ហើយកន្លែងចាស់នោះក៏គេមិនឲ្យនៅហ្នឹង ទៅនៅតាគីគេជម្លៀសទៅទៀតទៅ គេឲ្យទៅនៅផ្សេងទៀត ហើយអ្នកថ្មីគេឲ្យទៅនៅអូរតាគី អាហ្នឹងផ្លាស់ភូមិគ្នានៅ ។

ដានីៈ ចុះពូពេលដែលពូឃើញគេសម្លាប់ហ្នឹងប្រហែលក្នុងអំឡុងឆ្នាំណា?

មឿនៈ ប្រហែលជាឆ្នាំ៧៦,៧៧,៧៨ហ្នឹងឯង បើឆ្នាំ៧៨នេះពេញហ្នឹងសម្លាប់ច្រើនណាស់ មាន១០នាក់ ៥នាក់ មាន៦នាក់ ហើយមានសម្លាប់ក្នុងវត្តនោះក៏មាន ។

ដានីៈ វត្តណា?

មឿនៈ នៅវត្តអូរតាគី សម្លាប់រួចហើយគេចាក់ ដូចថាក្នុងចំណោមមួយពាន់នាក់ទាំងស្រីទាំងប្រុសគេថាខុសសិលធម៌សម្លាប់រួចគេចាក់វះខាងខ្នងឲ្យមើលណាអូន គេពុះខ្នងរួចគេយកថ្លើមចេញមកឲ្យមើលទាំងអស់គ្នាហ្នឹង ម៉ាចល័តទាំងអស់គ្នាព្រោះគេថាកុំឲ្យមានអ្នកយកគំរូតាម អាហ្នឹងខុសសិលធម៌ស្រលាញ់គ្នាតាមព្រៃតាមអី ។

ដានី៖ គេវះឲ្យយើងមើលតែម្ដង?

មឿន៖ បាទ! គេវះឲ្យយើងមើល កន្លែងហ្នឹងមួយ ហើយមានកន្លែងអូរតាកែ នៅនោះមនុស្សប្រុស ហើយមកអូរតាគីហ្នឹងទាំងស្រីទាំងប្រុស គេឲ្យយើងមើលកុំឲ្យយើងធ្វើខុសសិលធម៌ កុំឲ្យយើងស្រលាញ់គ្នា ហើយគេតាមចាប់ដល់ទៅពីរយប់ ។

ដានី៖ គេតាមចាប់ពីរយប់?

មឿន៖ បាទគេតាមចាប់តាមភ្លឺតាមស្រែ ដល់ពេលគេចាប់បានទៅគេហៅមនុស្សមកប្រជុំទាំងអស់គ្នាអាយប់មួយនៅវត្តអូរតាគីគេចាប់ទាំងស្រីទាំងប្រុសយកមកចង ឲ្យយកមើលដូចថាក្នុងចំណោមហ្នឹងគេឲ្យយើងមើលគេថាកុំឲ្យយើងយកយ៉ាងតាម ហើយប្រហែលជាដើមជ្រៃគេចងនៅហ្នឹងដើមជ្រៃ ហើយគេចងបែរមុខទៅដើមជ្រៃ ដែលគេនិយាយថាខ្នងចេញក្រៅ ហើយមុននឹងគេសម្លាប់គេឲ្យមើលមុខឲ្យចំ ដល់ពេលគេសម្លាប់គេចងទៅនឹងដើមឈើហ្នឹងទៅ ហើយគេពុះខាងខ្នង ។

ដានី៖ ពុះមនុស្សទាំងរស់ហ្នឹង?

មឿន៖ គេពុះទាំងរស់ ហើយគេស្រែកឈាមបាញ់ដូចស្អីអញ្ចឹង ។

ដានី៖ មានស្គាល់ឈ្មោះទេ?

មឿន៖ អត់មានស្គាល់ឈ្មោះទេ ស្គាល់តែកាលពីដើមតែមកដល់សព្វថ្ងៃនេះខ្ញុំចាំមិនបានទេ ស្គាល់ឈ្មោះទាំងស្រីទាំងប្រុស ។

ដានី៖ អ្នកនៅក្នុងភូមិហ្នឹងដែរឬក៏មិនមែនទេ?

មឿន៖ មិនមែនជាភូមិកំណើតរបស់គេទេ ពួកគេចល័តដូចជាពួកខ្ញុំដែរ ។

ដានី៖ អ្នកមកពីភ្នំពេញពីអីមក?

មឿន៖ បាទ! អ្នកមកពីឆ្ងាយអញ្ចឹងណា៎ អ្នកខ្លះមកពីកំពង់ចាម អ្នលភ្នំពេញអីមកបណ្ដើរៗនៅរួមគ្នាចល័ត ។

ដានី៖ នៅជិតវត្តអូរតាគីអូរតាកែ?

មឿន៖ កាលពីដើមនៅស្ពាននោះហ្នឹង ដល់ចេញពីក្បាលស្ពានទៅ ទៅនៅអូរតាកែ ដល់ពេលចេញពីអូរតាកែគេឲ្យទៅនៅផ្លូវខាងមុខលួស គេហៅភូមិខ្សែលួស ។

ដានី៖ កាលជំនាន់ស្លាប់ច្រើននោះជំនាន់ពីណាគេ ជំនាន់តាហៀក ឬក៏ជំនាន់ពីណាគេ?

មឿន៖ កាលជំនាន់តាហៀកនោះមធ្យមទេ ជំនាន់តាហៀកដូចថាគាត់មធ្យមទេ ដល់ពេលអ្នកក្រោយចូលមកគេហៅតាកង គេហៅតាកងមួយក្រុមឲ្យទៅរៀនសូត្រអញ្ចឹងណា៎ ។

ដានី៖ បាទ!

មឿន៖ ជួនកាលទៅរៀនសូត្រអត់មានបានទៅវិណា ហួសទៅល្អានផ្កាស្វាអីណាណោះ បើយកទៅច្រើនគេដឹកទៅខាងនោះ ។

ដានី៖ ដល់ក្រោយពីតាហៀកហ្នឹងពីណាគេមកកាន់?

មឿន៖ ក្រោយពីតាហៀកគេហៅតាអីទេ តាហ្នឹងខ្មៅ ។

ដានី៖ តាហ្នឹងគាត់មកពីណាមក?

មឿន៖ តាហ្នឹងមកពីភូមិភាគនារតី ។

ដានី៖ មកពីភូមិភាគនារតី?

មឿន៖ បាទ! ខ្មៅណាស់តាហ្នឹង តែខ្ញុំវាមិនចាំឈ្មោះ ។

ដានី៖ កាចទេ?

មឿន៖ កាចណាស់ កាចជាងតាហៀក ។

ដានី៖ កាចជាងតាហៀក?

មឿន៖ បាទ! ក្រោយពីតាហៀកស្លាប់រួចហ្នឹង តាហៀកកាលហ្នឹងគេយកទៅសម្លាប់តែមិនដឹងថាសម្លាប់នៅណាទេឮតែគេថាយកទៅរៀនសូត្រ តាហៀក តាសឿន តាកុក ៣នាក់ហ្នឹងគេយកទៅថាទៅរៀនសូត្រហើយគេយកដាក់ឡានទៅ ។

ដានី៖ អញ្ចឹងកាលហ្នឹងពូនៅអូរតាគីអូរតាកែដឹងថាគេយកមកសម្លាប់នៅកន្លែងភ្នំសំពៅកន្លែងល្អានផ្កាស្វាហ្នឹងដែរ?

មឿន៖ ដឹង ។

ដានី៖ ម៉េចបានជាពូដឹង?

មឿន៖ ដឹងត្រង់ថាមានអ្នកចល័តខាងនោះហើយគេមកនៅខាងនេះ ថាដឹកទៅពីនេះហើយយកទៅណាៗគេដឹងទាំងអស់ ហើយពួកដែលមកនៅជាមួយខ្ញុំនេះគេចល័តឯ ជើងភ្នំសំពៅនោះ ដល់ពេលគេឲ្យនេះមកគេមកលើកនៅអាងកំពីងពួយ គេមកជុំគ្នានៅអាងកំពីងពួយទាំងអស់ប្រហែលជាជាប់ ២០០០០០នាក់ណា ។

ដានី៖ មនុស្សច្រើន?

មឿន៖ បាទ! មនុស្សរាប់សែនណាអូន ព្រោះដូចថាក្រុមនេះមួយក្រុម ដូចថាគ្នាតទៅប្រវែងទៅនោះតែអាទៅនេះវាធំហើយខ្ពស់ ក្នុង២ឆ្នាំនោះបានលើកគ្រប់២ឆ្នាំ មួយឆ្នាំបាន៣ខែ លើកទំនប់ទម្រាំតែបានរួច ។

ដានី: ហូបចុកអីយ៉ាងម៉េចដែរ?

មឿនៈ ហូបចុកគឺបបរ ។

ដានី: មានកម្លាំងធ្វើការដែរ?

មឿនៈ អត់មានទេ ធ្វើបានមួយដើងៗ គេចេះតែឈរមើល អត់ហ៊ានឈប់ទេទៅមុខទៀតហើយ ស៊ូទៅចេះតែស៊ូចេះតែទំទៅ ធ្វើយ៉ាងម៉េចក៏ដោយឲ្យតែជីវិតរស់នៅ ។

ដានី: ចុះពូធ្លាប់ជួបតាគឹម នៅម្ដុំណា?

មឿនៈ តាគឹមគាត់នៅអណ្ដូងព្រីង ។

ដានី: គាត់ធ្វើអី?

មឿនៈ មិនដឹងជាគាត់កាន់ខាងមុខងារអីទេ គ្រាន់តែឃើញគាត់កាន់កាំភ្លើងមួយដើម តែមិនមែនកាំភ្លើងវែងទេគឺកាំភ្លើងខ្លីហើយបង់កន្សែងក្រហម តែមិនដឹងគាត់មានមុខការមុខងារអីគាត់ទេព្រោះមិនសូវបានចាប់អារម្មណ៍ ។

ដានី: ពេលពូជាប់គាត់នៅហ្នឹងពូធ្វើការនៅអូរតាគីអូរតាកែ?

មឿនៈ មកជួបគាត់នៅកន្លែងនេះហ្នឹង?

ដានី: បាទ!

មឿនៈ មកជួបនៅហ្នឹងគេយកចល័តហ្មង គេមកជួយអាត្រង់នេះ ។

ដានី: ជួយអីគេ?

មឿនៈ ដែលស្រូវនៅខាងវាលពោធិ៍ វាលពោធិ៍គឺវានៅហួសអណ្ដូងព្រីង គេហៅវាលពោធិ៍ ហើយខ្ញុំចល័តមកនេះហើយមកចំចល័តដែលគាត់កាន់កាប់នៅក្នុងម្ដុំនេះហ្នឹង ហើយក៏ឃើញនៅទីហ្នឹង ។ ហើយគេយកចល័តហ្នឹងមកធ្វើច្រូត ធ្វើច្រូតម្ដុំវាលពោធិ៍នោះ ។

ដានី: ហើយពេលឃើញគាត់ស្គាល់ឈ្មោះគាត់ទេ?

មឿនៈ ស្គាល់ព្រោះគេប្រាប់ អាវឿងចល័តគេនៅនោះណា ។

ដានី: ហើយរាងគាត់យ៉ាងម៉េចដែរ?

មឿនៈ រាងគាត់ធម្មតា កំពស់កំពអី ។

ដានី: មាឌតូចឬធំ ហើយសអីខ្មៅ?

មឿនៈ មិនមែនជាសប៉ុន្មានទេ សម្បុរសណ្ដែកបាយ ។

ដានី: ហើយចុះមាឌគាត់?

មឿនៈ មាឌគាត់ធំមិនធំ តូចមិនតូច មាឌល្មម ។

ដានី៖ មាឌប៉ុនពូឬក៏តូចជាងពូ?

មឿន៖ ទេមិនមែនប៉ុនខ្ញុំទេ គេធំជាងខ្ញុំ ហើយឃើញដោយសារគេប្រាប់ទេ បើថាតួអង្គឲ្យស្គាល់គាត់ច្បាស់ហ្នឹងមិនស្គាល់ទេ តែកាលហ្នឹងគេប្រាប់ថានេះតាគីម កាលហ្នឹងអ្នចល័តដូចគ្នាគេប្រាប់ ។

ដានី៖ ហើយចុះពូកាលជំនាន់ហ្នឹងមានបានជួបឪពុកម្ដាយជួបបងប្អូនទេ?

មឿន៖ ជួបបងជួបប្អូននៅកន្លែងនោះដែរតែគ្រាន់ថាផ្ញើកន្លែងឲ្យផ្សេងគ្នា ម្ដាយពូនោះគាត់នៅខាងក្រុមចាស់ៗគាត់នៅសហករណ៍ផ្សេងទៅ ហើយខ្ញុំនេះគេជូនទៅខាងចល័តផ្សេងទៅ កាលហ្នឹងនៅផ្សេងគ្នាមិនបាននៅជាមួយគ្នាទេ ។

ដានី៖ អញ្ចឹងពូនៅចល័តរហូតទាល់តែបែក?

មឿន៖ ខ្ញុំនៅចល័តរហូតទាល់តែគេចូលព្រៃ ។

ដានី៖ កាលហ្នឹងពូអត់ទាន់មានប្រពន្ធទេ?

មឿន៖ អត់ទាន់មានទេ ។

ដានី៖ ហើយម៉េចបានជាគេកៀរចូលព្រៃ គេកៀរទាំងអស់?

មឿន៖ បាទ! គេកៀរទាំងអស់ ម៉ាចល័តគេកៀរទាំងអស់ទៅណា ហើយគេរាប់ខ្ទះដូចថាអ្នកណានេះគេវ៉ៃនៅបាត់ដំបង ដល់ពេលមួយក្រុមទៀតអ្នកណានេះក៏វាកៀរចូលតាមវាទៅ ។

ដានី៖ កៀរមក?

មឿន៖ បាទ! ឲ្យទៅនៅព្រៃជាមួយវា ។

ដានី៖ ពេលកៀរហ្នឹងមានប្រាប់ថាម៉េចទេ?

មឿន៖ ពេលគេកៀរហ្នឹងគេប្រាប់ថាយួនចូលមកដល់ហើយ ឥលូវយើងនាំគ្នារត់ ពួកមិត្តយើងអញ្ចេះអញ្ចោះក៏ដោយទៅហ្នឹងគេទៅ ដូចថាយើងវាល្ងង់ខ្លៅមិនដឹងធ្វើយ៉ាងម៉េចចេះតែតាមគេទៅ ។

ដានី៖ ចេះតែតាមគេទៅ?

មឿន៖ បាទ!

ដានី៖ តាមរហូតដល់ណាទៅ?

មឿន៖ តាមរហូតដល់កំពីងពួយ ហើយម្ដុំកំពីងពួងអត់មានអីទេ មានតែវាល មានតែប្រេង ដល់ពេលចេញពីកំពីងពួយទៅគេនាំដើរដល់ព្រំដែនហើយចេះតែទៅៗឆ្ងាយទៅដល់ព្រំដែនម៉ាឡៃ ។

ដានី៖ ទៅដល់ព្រំដែនម៉ាឡៃ?

មឿន៖ បាទ! ដល់ពេលខ្សែម៉ាឡៃគួសខ្សែបន្ទាត់ហើយទៅមកនៅភ្នំឆ័ត្រវិញ ។

ដានី៖ ហើយយ៉ាងម៉េចទៀតទៅដល់ពេលមកនៅភ្នំឆ័ត្រ?

មឿនៈ មកនៅភ្នំពេញក៏នៅហើយប្រជាជនគេជាទ័ពគេអញ្ចឹងណា ហើយពេលគេត្រូវការសម័យនោះគេមាន ដូចថាគេចូលដល់សម័យគេគេនាំគ្នាវៃជាមួយយួនជាមួយវៀតណាម វាចេះតែនាំគ្នាមកវៃតាមស្រុកតាមស្រែ កាលត្រូវប្អូនៗ ប៉ះអ្នកណាអត់អង្ករហើយនាំគ្នាសម្លុតប្រជាជន ។

ដានី: ពេលមកនៅភ្នំពេញធ្វើអីទៅ?

មឿនៈ ពេលមកនៅភ្នំពេញធ្វើជាទាហាន អាទាហានខ្មែរក្រហម ។

ដានី: អ៎ធ្វើទាហានខ្មែរក្រហម?

មឿនៈ បាទ!

ដានី: កាលហ្នឹងនៅក្នុងក្រុមកងណា?

មឿនៈ កាលហ្នឹងម្តុំហ្នឹងមានពួកតាស៊ូ ។

ដានី: មានតាស៊ូ?

មឿនៈ បាទ! តាស៊ូហ្នឹងគាត់កាន់តូចទេ បើមេគេហ្នងតាហាន ។

ដានី: ឈ្មោះហាន?

មឿនៈ បាទ! ហើយចេញពីហានមកមានកង៥២នោះអាប៉ិចៃជាអ្នកកាន់ កាន់អញ្ចឹងខ្ញុំចេញពីប៉ិចៃនោះមកបានជាខ្ញុំមកនៅប៉ាវ៉ា ។

ដានី: ហេតុអីបានជាពូដូរមកនៅប៉ាវ៉ា?

មឿនៈ មើលទៅសម័យនោះខ្មែរក្រហមដូចថាវាដូចថាការកំណត់របស់គេវៃវាអត់មានពេលស្រាកស្រាន្ត ឲ្យតែជួបនៅណាគេវៃនៅនោះហើយ ហើយយើងចេះតែខ្លាច ហើយមើលទៅប៉ាវ៉ាដូចគេនៅស្រួល ហើយសម័យនោះប៉ាវ៉ាបើកចំហហើយបើកលុយឲ្យគេគ្រប់គ្រាន់ ដូចតាសៀនសានគាត់កាន់ម្ខោះហើយគាត់ចេះតែបញ្ជូនដូចជាអង្ករ ដូចជារបស់របរអី ការៀនសូត្រ តែបើខ្មែរក្រហមគេរាងតឹងតែង ដល់ពេលតឹងតែងអញ្ចឹងក៏នាំគ្នាចូលមកនៅប៉ាវ៉ាវិញទៅ ។

ដានី: ខ្មែរក្រហមអត់ថាអីទេ?

មឿនៈ លួចរត់ ។

ដានី: លួចគ្នាប៉ុន្មាននាក់?

មឿនៈ គ្នា៥នាក់ ។

ដានី: គ្នា៥នាក់?

មឿនៈ បាទ!

ដានី: ពីណាគេខ្លះពូមានចាំទេ?

មឿនៈ ចាំខ្វះ ចាំប្រហែលជា៣,៤នាក់ ឈ្មោះអាសុកមួយ ឈ្មោះ មាំមួយ ហើយអ្នកណាគេមួយទៀតទេចាំតែប៉ុណ្ណឹង ព្រោះវាយូហើយតាំងពីសម័យនោះមកដល់សម័យនេះវាល្ងមភ្លេចហើយ ហើយណាមួយសព្វថ្ងៃនេះវាភ្លេចមុខភ្លេចក្រោយ ។

ដានីៈ ចុះពូកាលនៅភ្នំឆ័ត្រនៅជាមួយខ្មែរក្រហមនៅជាមួយតាស៊ូនៅកងពលលេខប៉ុន្មាន?

មឿនៈ នៅកងពលលេខប៉ុន្មានទេកាលហ្នឹង នៅជាមួយតាស៊ូ តែគាត់កាន់រួម ។

ដានីៈ កាន់រួមហ្នឹងដល់ក្រោយមកពូមកនៅកងពល៥២?

មឿនៈ បាទ! ខ្ញុំនៅកងពលលេខ៥២ ។

ដានីៈ កងពលលេខ៥២ហ្នឹងពីណាគេប្រធាន?

មឿនៈ ប្រធានកងពលបើនិយាយរួមទៅមិនព្រចថាជាប្រធានកងពលផង កងពលក្នុងកងពលតាស៊ូ គ្រាន់តែថាខ្ញុំមកនៅក្នុងវរៈសេនាធំអញ្ចឹងណា កងពលនោះគេកាន់កងតូចដូចថាមួយខេត្តនោះទាំងអស់អញ្ចឹងណា នៅក្នុងតាស៊ូរួមតែមួយណា ហើយចូលមកនៅ៥២នេះលេខ៥២លេខវរៈសេនាធំអីមិនដឹងទេព្រោះនៅក្នុងនោះគេដាក់អញ្ចឹង លេខវរៈសេនាធំគេហៅតែ៥២ហ្នឹង ។

ដានីៈ នៅឆ្នាំណាដែលពូរត់មកចូលប៉ៃលិនហ្នឹង?

មឿនៈ ឆ្នាំ៨២ ឆ្នាំ៨២ហ្នឹងខ្ញុំមកនៅប៉ៃលិន ។

ដានីៈ នៅប៉ៃលិនហ្នឹងគេហៅកងអីគេ?

មឿនៈ បើនិយាយទៅជុំរំដែលនៅនោះគេហៅជុំរំអូរបុក ហើយវាមានច្រើនជុំរំ មានប៉ៃលិន មានណងចាន់ មានឫទ្ធិសែនអញ្ចឹងណា កាលសម័យនោះវាមិនមាននេះទេ ប៉ុន្តែគ្រាន់ថាជុំរំដែលខ្ញុំនៅនោះនៅក្នុងអូរបុក ។

ដានីៈ ប្រធានឈ្មោះអីនៅជុំរំអូរបុក?

មឿនៈ ប្រធានគេឈ្មោះសុភ័ក្ត្ររចនា ។

ដានីៈ ឈ្មោះសុភ័ក្ត្ររចនា?

មឿនៈ បាទ!

ដានីៈ ច្រើនទេកាលហ្នឹងប៉ៃលិន?

មឿនៈ ច្រើនដែរអូកាលហ្នឹងហាត់១០០០នាក់ជាង ។

ដានីៈ ដល់ពេលយើងរត់ទៅចូលអញ្ចឹងគេឲ្យចូលដែរ?

មឿនៈ បាទ! អត់មានអីទេគេទទួលដែរ ។

ដានីៈ នៅម្តុំណាជុំរំអូរបុកហ្នឹង?

មឿនៈ ជំរុំអូរបុកមកនៅខាងជើងពងទឹក ហើយទៅនៅលើភ្នំនោះ ។

ដានីៈ នៅលើភ្នំណា?

មឿនៈ នៅលើភ្នំដងរែក ។

ដានីៈ នៅលើភ្នំដងរែកហ្នឹង?

មឿនៈ បាទ! នៅលើភ្នំដងរែកយើងខាងបន្ទាយឆ្មា ហើយយើងចេញពីបន្ទាយឆ្មាទៅខាងជើងមានភូមិដែលគេហៅភូមិពងទឹកយើងនេះណា៎ តែនៅលើភ្នំនៅតាមភ្នំដងរែកនេះ ។

ដានីៈ ម៉េចទៅពេលដែលពូចូលប៉ុភ្ហ៊ា ស្រួលជាងនៅជាមួយខ្មែរក្រហម?

មឿនៈ បាទ! ស្រួលជាងហើយវិន័យវាមិនសូវតឹងតែងណា៎ ហើយបានហូបបានចុកគ្រប់គ្រាន់ ហើយនៅខ្មែរក្រហមដូចថាថ្ងៃនេះយើងត្រូវទៅយកការណ៍នេះ ហើយត្រូវទៅយកការណ៍នោះគឺត្រូវតែទៅ បើមិនទៅខូចគេ ។

ដានីៈ បើប៉ុភ្ហ៊ាអត់អីទេ?

មឿនៈ ប៉ុភ្ហ៊ាអត់អីទេ អាចសុំគេបាន អាចតវ៉ាបានអាចប្រាប់ថាអញ្ចេះអញ្ចោះគេអត់ថាអីទេ សម័យនោះដូចថាជំរុំនោះមានតែជំរុំមកខាងកើតនេះ ហើយតាសឿន សានគាត់កាន់ទៅរហូតទៅទាល់អំពិលយើងរហូតទៅទាល់ចុងសាន បើថាចាប់ពីអូរកុងទៅកើតនេះមានតែជំរុំសម្ដេច មួយប៉ែក ៗម្នាក់ចែកខ័ណ្ឌគ្នា ។

ដានីៈ ពេលវ៉ៃហ្នឹងមានសហការណ៍ជាមួយខ្មែរក្រហមដែរអត់?

មឿនៈ ជួនពេលខ្លះត្រូវគ្នា ហើយជួនពេលខ្លះមិនត្រូវគ្នាអញ្ចឹងក៏វ៉ៃគ្នាទៅ វ៉ៃប៉ុភ្ហ៊ានឹងខ្មែរក្រហមក៏មានហើយធ្លាប់នៅក្នុងព្រៃអញ្ចេះប៉ះគ្នាវ៉ៃគ្នា ពេលនោះវាមិនទៀងទាត់ទេ ពេលណាខឹងគ្នាដាក់គ្នាទៅខ្មែរក្រហមហើយនឹងប៉ុភ្ហ៊ាព្រោះនៅក្នុងព្រៃដូចគ្នា ហើយសហរការណ៍នោះសហការណ៍ក្រោយគេចេញបំបែកពីជំរុំអូបុងនោះតាសឿន សានគាត់ប្រមូលទៅនៅអំពិលនោះទាំងអស់គ្នាទៅនៅទាំងអស់គ្នាដូចជាកូនទាំងអស់គ្នា ហើយឃើញបែកមកសាមគ្គីគ្នាត្រង់ពេលវ៉ៃនៅម្ដុំថ្មពួកនៅម្ដុំយើងជាយៗដែននេះសរុបរួមដៃគ្នា បើកាលពីដើមមិនដែលរួមដៃគ្នាទេឲ្យតែជួបគ្នាដឹងតែពីវ៉ៃគ្នា ។

ដានីៈ រហូតដល់ពេលណាទៅបានពូចូលមកនៅហ្នឹង?

មឿនៈ ចូលមកកាលឆ្នាំ៩៣ ។

ដានីៈ ៩៣?

មឿនៈ បាទ! ឆ្នាំ៩៣ កាលហ្នឹងមានលោកគ្រូវត្តនេះគាត់មកតាមប្រពន្ធកូន ហើយខ្ញុំក៏បែកចេញពីគាត់

ដានី: ពូឈប់ពីប៉ារ៉ាតាំងពីឆ្នាំណាមក?

មឿនៈ ពីឆ្នាំ៩៣ហ្នឹងឯង ។

ដានី: ឆ្នាំ៩៣ហ្នឹងឈប់រហូត?

មឿនៈ បាទ! សម័យនោះគេឲ្យកាន់កោះធំ ។

ដានី: តែប៉ារ៉ាហើយខ្មែរក្រហមដែលឈ្មោះគ្នាដែលវ៉ៃគ្នាដែរ?

មឿនៈ ដែលឈ្មោះដែលវ៉ៃគ្នាតើ ។

ដានី: ម៉េចបានជាឈ្មោះវ៉ៃគ្នា?

មឿនៈ ទេមិនដឹងម៉េច កាលហ្នឹងខ្មែរក្រហមធ្វើក្រឡេចក្រឡុច បើថាខ្ញុំស្មៀនតាមដូវអីជួបប៉ារ៉ា ខទាហរណ៍ថាចុះមកនេះទាំងអស់គ្នាអញ្ចឹងឲ្យតែនេះវាស្ទាក់វ៉ៃហើយ វាធ្វើបន្ទំវៀតណាមអីនោះ ស្ទាក់វ៉ៃយកអីវ៉ៃតវ៉ាន់យើង មិនដឹងម៉េចវាទេ ប្រហែលជាគោលការណ៍របស់វាហើយ ។

ដានី: ហើយឆ្នាំ៩៣ពូមកនៅហ្នឹង ម៉េចបានជាពូអត់ទៅនៅស្រុកកំណើត?

មឿនៈ បានប្រពន្ធនៅហ្នឹង ។

ដានី: ពូរៀបការនៅឆ្នាំណា?

មឿនៈ បានកាលនៅជំរុំនេះឯងអូន កាលពីដើមអត់ទាន់បានទេ បានកាលឆ្នាំ៧៩ ឆ្នាំហ្នឹងដូចថាគេចូលមកអស់អញ្ចឹងហើយពេញទឹកពេញដី តែបាននៅក្នុងជំរុំខ្មែរក្រហមនោះឯង ។

ដានី: ពូចាប់ពីឆ្នាំ៩៣មកនៅហ្នឹងអត់មានដែលបានធ្វើអីទៀតទេ?

មឿនៈ អត់ដែលធ្វើអីទេអូន ។

ដានី: ចុះផ្ទះនៅប៉ារ៉ាហ្នឹងមុខព្រួញពីណា?

មឿនៈ មុខព្រួញដែលថាចុះមកធ្វើការ ចុះមកធ្វើការនៅខ្មែរចាប់ពីនេះមករហូតដល់កំពង់ធំ ។

ដានី: រហូតដល់កំពង់ធំ?

មឿនៈ បាទ! ចាប់ពីបន្ទាត់ខ្សែរចេញពីនេះទៅ ទៅដល់មុខច្រកយើងស្រីស្នំ ហើយចេញពីស្រីស្នំទៅ ទៅដល់បន្ទាយស្រីភ្នំគូលេន ចេញពីភ្នំគូលេនទៅត្រពកអ័រ ចេញពីត្រពកអ័ទៅដល់ត្រពាក់ស៊ីងសែន ។

ដានី: ប៉ុន្តែកាលហ្នឹងវ៉ៃមិនសូវខ្លាំងទេ?

មឿនៈ ប៉ារ៉ាមិនសូវជាវ៉ៃខ្លាំងប៉ុន្មានទេ គេវ៉ៃបន្តិចៗហ្នឹងគេមិនសូវជាក្លាហានប៉ុន្មានទេ បើខ្មែរក្រហមគេមានកងទ័ព គេបង្កើតកងទ័ពគេពាសណាពាសណី បើត្រូវវ៉ៃគេវ៉ៃ បើប៉ារ៉ាបានតែម៉ាល្មមៗហ្នឹង បើថាជួបអីទៅបានតែម៉ាវ៉ៃដោះខ្លួន ។

ដានី៖ ចុះមេប្រធានរបស់ពូឈ្មោះអីគេ ឈ្មោះអីគេកាលប្រធានអូរបុក?

មឿន៖ ឈ្មោះសុភ័ក្ត្ររចនា ។

ដានី៖ ហើយសុភ័ក្ត្ររចនាគាត់ទៅណាទៅ?

មឿន៖ សុភ័ក្ត្ររចនាហ្នឹងខ្ញុំបាត់ឈ្មោះគាត់មិនដែលឮ ។

ដានី៖ អត់ដែលឮទៀតទេ?

មឿន៖ បាទ! អត់ដែលឮទេ ហើយឈ្មោះអោក សេរីសុភ័ក្ត្រនោះដផកាលសម័យនោះ វី សាម៉េត នោះដផ ហើយអ៊ំដេតមិនដឹងទៅណាទេ ។

ដានី៖ ពូតាំងពីមកនៅនេះ៩៣មកឈប់ហើយ?

មឿន៖ បាទ! ឈប់រវីរវល់ហើយ មានតែប្រកបរបរធ្វើស្រែបន្តិចបន្តួចគ្រាន់ចិញ្ចឹមកូន ។

ដានី៖ ពូធ្លាប់ទៅលេងស្រុកវិញដែរទេ?

មឿន៖ បានទៅលេងម្តងកាលបងប្អូនគាត់ស្លាប់ អត់មានដីធ្លីអីទេ ម៉ែគាត់បែងចែកមានតែដីហ្នឹង ។

ដានី៖ ឥលូវអត់មានបងប្អូនទៀតទេ?

មឿន៖ អត់មានទេ ។

ដានី៖ អស់ហើយនៅស្រុក?

មឿន៖ អស់ហើយ មានតែក្មួយៗ ។

ដានី៖ អញ្ចឹងពូលែងទៅហើយ?

មឿន៖ មានទៅម្តងមួយយាមដែរ ហើយឥលូវនេះខ្ញុំមិនសូវស្រួលដែរហ្នឹង ទៅម្តងមួយយាមពេលណាដែលខ្ញុំនឹកអញ្ចឹង ។

ដានី៖ ពូមានដែលឮគេកាត់ទោសមេដឹកនាំខ្មែរក្រហមជាន់ខ្ពស់អីទេ?

មឿន៖ ឮដែរ ឮតាមវិទ្យុ ។

ដានី៖ គ្រាន់តែឮតាមវិទ្យុ?

មឿន៖ បាទ!

ដានី៖ ដែលមើលទូរទស្សន៍គេកាត់ទោសឌុចដែរឬអត់?

មឿន៖ មិនបានឃើញទេតាមទូរទស្សន៍ ព្រោះប្រើកាកាល័រធំនោះវាអត់មានភ្លើង ។

ដានី៖ ហើយចុះពូមានស្គាល់ឌុចទេ?

មឿន៖ ឌុចខ្ញុំស្គាល់តាមជារូបភាពធម្មតាទេ តែកាលគាត់នៅឆ្នាំមួយជួរខាងនេះគេស្គាល់គាត់ទាំងអស់ ។

ដានី៖ មួយជួរហ្នឹងគេស្គាល់ទាំងអស់?

មឿនៈ បាទ! ព្រោះគាត់នាំប្រពន្ធគាត់មកនៅផ្ទាំនេះ គាត់បង្រៀននៅហ្នឹងផ្ទាំនេះ ។

ដានីៈ គាត់ឈ្មោះអីកាលគាត់នៅផ្ទាំ?

មឿនៈ មិនដឹងឈ្មោះអីទេ ព្រោះកាលហ្នឹងខ្ញុំអត់មានបានសួផង ។

ដានីៈ ពូអត់ដែលបានជួបគាត់ទេ?

មឿនៈ ទេខ្ញុំមិនដែលបានជួបទេ នៅម្តុំនេះគេស្គាល់គាត់គ្រប់គ្នាព្រោះគាត់មកនៅបង្រៀននេះ ។

ដានីៈ បើពូអត់ដែលបានឃើញទេ?

មឿនៈ អត់ទេ មិនដែលបានឃើញទេ ឃើញតែរូបភាព ។

ដានីៈ ហើយពូយល់ឃើញយ៉ាងម៉េចដែរ ដែលគេកាត់ទោសមេដឹកនាំខ្មែរក្រហមជាន់ខ្ពស់?

មឿនៈ បើតាមខ្ញុំគិតទៅឃើញថាវាសមរមល្មមដែរនឹងការប្រព្រឹត្តិរបស់គាត់ ឆ្នាំកំណត់ដែលថាឲ្យគាត់ជាប់គុកវាសមនឹងអាយុរបស់គាត់ព្រោះគាត់ចាស់ហើយ ។

ដានីៈ ពូថាយុត្តិធម៌ឬមិនយុត្តិធម៌ក្នុងការកាត់ទោសហ្នឹង?

មឿនៈ បើតាមខ្ញុំគិតទៅក្នុងនាមខ្ញុំជាអ្នកជួបការលំបាកពីដើមមកកាលសម័យនោះហើយមកចូលសម័យនេះដូចជាមានចិត្តរំសាយទៅ បើភាពយុត្តិធម៌វាត្រឹមត្រូវហើយ អាហ្នឹងមិនមែនបានមើលទូរទស្សន៍ទេណា៎គ្រាន់តែស្តាប់វិទ្យុទេ ។

ដានីៈ ចុះពូរឿងរ៉ាវដែលពូនិយាយថាកាលពីជំនាន់ពាឆ្នាំវាពិបាកវេទនា មានគេសម្ងាប់អីពូមានដែលធ្លាប់និយាយប្រាប់កូនៗឲ្យស្តាប់ទេ?

មឿនៈ បាទ! ខ្ញុំប្រាប់ដែរ ប្រាប់ពួកនោះថាក្នុងសម័យនោះវាលំបាកលំបិនអញ្ចេះៗប្រាប់កូន ឲ្យកូនដឹងតៗគ្នាកុំឲ្យវានេះពេក ឯរឿងពីដើមមកវាមិនមានការសប្បាយដូចកូនក្មេងសព្វថ្ងៃ មានប្រលើសបើស អាខ្លះមានបង្ហោះម៉ូតូ មានចាក់កាប់គ្នាអីហ្នឹង កាលពីដើមមកវាមិនដែលមានអញ្ចឹងទេមានតែការនឿយហត់ មានតែការលំបាកគ្មានការសប្បាយអញ្ចឹងទេ មានតែបបរមួយថ្ងៃពីរវែក មានពេលព្រឹកហើយនឹងពេលល្ងាច បើថ្ងៃត្រង់អត់មានទេ ខ្ញុំអត់មានអីទេមានតែប្រដៅប្រដៅកូនតែប៉ុណ្ណឹង ។

ដានីៈ ពេលពូប្រាប់កូន កូនពូជឿទេ?

មឿនៈ កូនជឿដែរហ្នឹង ប្រាប់កូនថាសម័យឪពុកអញ្ចេះៗ ហើយគ្រាន់តែថាវាស្តាប់ពុសម័យប៉ុល ពតហ្នឹងវាប៉ុល ពតហ្នឹងគេទៅពួកក្មេង ហើយបើខ្ញុំហ្នឹងវាគ្រប់សព្វហើយរហូតចាប់ពីសម័យនោះមកដល់សម័យនេះ បើនិយាយទៅសម័យសង្គមរាស្ត្រនិយមពីដើមមករហូត សម័យស្អីគេទេកាលសម័យនោះខ្ញុំទាន់តើ ។

ដានី៖ អញ្ចឹងខ្ញុំសូមអរគុណច្រើនដែលបានចំណាយពេលសំណេះសំណាលជាមួយខ្ញុំ ។

មឿន៖ បាទ!

«ចប់»